# សុន្ទរកថា

## ឯកឧត្តម សុខ ចិន្តាសោភា ឧបនាយករដ្ឋមន្ត្រី
## តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត
## ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍
## ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ (លើកទី៣២ នៅកម្ពុជា)
## ក្រោមប្រធានបទ «យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍»

ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
សាលសន្និសីទចតុមុខ, ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥

- **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា ថ្នាក់ដឹកនាំក្រសួងស្ថាប័ន
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានាប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោកស្រី Patricia Ongpin នាយិកាអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្មួយៗយុវជនទាំងអស់ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសបំផុត និងមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិក្មួយៗ នៅក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» ដ៏មហោឡារិកនាពេលនេះ ។

ក្នុងនាម **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ដែល **សម្តេច** ក្នុងឋានៈជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ដែលចាប់តាំងពីមានការរាតត្បាតនៃមេរោគអេដស៍ និងជំងឺអេដស៍នាឆ្នាំ១៩៩១ រហូតដល់បច្ចុប្បន្ន **សម្តេច** បានលះបង់អស់កម្លាំង កាយចិត្ត ប្រាជ្ញាដឹកនាំ និងចូលរួមដោយផ្ទាល់ក្នុងការពង្រីកភាពឆ្នើមដល់បណ្តាញកាកបាទក្រហមគ្រប់លំដាប់ថ្នាក់ នៅទូទាំងប្រទេស ប្រយុទ្ធប្រឆាំងនឹងការមាក់ងាយ រើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ផ្តល់ការជួយឧត្ថម្ភគាំទ្រដល់ប្រជាជនរងគ្រោះដោយសារមេរោគអេដស៍និងជំងឺអេដស៍ ធ្វើឱ្យប្រសិទ្ធភាពនៃការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាកាន់តែមានកម្រិតខ្ពស់ថែមទៀត។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំ សូមពាំនាំនូវការកោតសរសើរ និងអរគុណពី **សម្តេចធិបតីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត** ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការដឹកនាំរបស់**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ដែលបានធ្វើឱ្យសម្រេចនូវសមិទ្ធផលធំៗជាច្រើន ក្នុងការកាត់បន្ថយការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាក្នុងឆ្នាំ២០២៥នេះ។ ខ្ញុំសូមថ្លែងនូវអំណរគុណចំពោះ សម្តេច ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្ថាប័នព្រឹទ្ធសភា រដ្ឋសភា កាកបាទក្រហមកម្ពុជា អង្គការសង្គម ស៊ីវិល វិស័យសាសនា វិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ និងបងប្អូនជនរួមជាតិទាំងអស់ ដែលបានចូលរួមគាំទ្រ និងខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតីប្រកបដោយឆន្ទៈមោះមុត និងការប្តេជ្ញាខ្ពស់ធ្វើឱ្យការងារឆ្លើយតបនឹងមេរោគ

អេដស៍ និងជំងឺអេដស៍ ទទួលបាននូវលទ្ធផលជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ ហើយយើងពិតជាមានក្ដីសង្ឃឹមថា យើងអាចធ្វើដំណើរឆ្ពោះទៅសម្រេចបាននូវគោលដៅ «សូន្យបី» (សូន្យការឆ្លងថ្មីនៃមេរោគអេដស៍ សូន្យការស្លាប់ដោយសារជំងឺអេដស៍ និងសូន្យការមាក់ងាយ រើសអើង) និងគោលដៅ «**គោលដៅ ៩៥ ៩៥ ៩៥**» (៩៥% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ៩៥% នៃអ្នកដែលដឹងស្ថានភាពផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង៩៥% នៃអ្នកដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានបន្ទុកមេរោគអេដស៍កម្រិតទាប) តាមកាលកំណត់ ទោះបីកម្ពុជាយើងបាន និងកំពុងទទួលរងនូវឥទ្ធិពលជាអវិជ្ជមានពីការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច របាំងពាណិជ្ជកម្ម បច្ចេកវិទ្យា និងការប្រែប្រួលប្រជាសាស្ត្រជាដើម។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវជាទីរាប់អាន!**

តាមរយៈសារលិខិតរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសាររបស់ **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងរបាយការណ៍របស់ **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ព្រមទាំងចំណាប់អារម្មណ៍របស់លោកស្រី Patricia Ongpin នាយិកាអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា តំណាងអង្គការសង្គមស៊ីវិល នៃគណៈកម្មាធិការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ រួមទាំងចំណាប់អារម្មណ៍របស់តំណាងបងប្អូនគ្រួសាររងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នាពេលមុននេះ គឺជាសក្ខីភាពជាក់ស្តែងមួយ ដែលបានបញ្ជាក់យ៉ាងច្បាស់ថាទស្សនៈរបស់យើងក្នុងការកសាងសង្គមមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍អាចសម្រេចទៅបាន និងមានន័យថាកម្ពុជាកំពុងតែស្ថិតនៅលើផ្លូវត្រូវ ដែលនឹងឈានទៅសម្រេចបាននូវកម្មវត្ថុដែលបានកំណត់ក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល គឺៈ ១)កាត់បន្ថយការឆ្លងថ្មីនៃមេរោគអេដស៍ឱ្យបានតិចជាង១នាក់/ថ្ងៃ ឬក្នុងរង្វង់ជាង២០០នាក់/ឆ្នាំ ២)កាត់បន្ថយការស្លាប់ដោយសារអេដស៍ឱ្យបានតិចជាង២០០នាក់/ឆ្នាំ និង ៣) លុបបំបាត់ការរើសអើង និងការមាក់ងាយអ្នកផ្ទុកមេរោគអេដស៍។

តាមរយៈរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅឆ្នាំ២០២៤ កម្ពុជាសម្រេចបាន៩២-១០០-៩៨ ធៀបនឹងគោលដៅ ៩៥-៩៥-៩៥ ដែលកំណត់ដោយអង្គការសហប្រជាជាតិ UNAIDS នៅឆ្នាំ២០៣០។ ចំនួនអ្នកឆ្លងថ្មីនៃមេរោគអេដស៍មាន១ ២០០ករណី បានថយចុះពី១៤ ០០០ករណី នៅឆ្នាំ១៩៩៧។ ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍មាន១ ០០០ករណី បានថយចុះពី ៤ ៧០០ករណី នៅឆ្នាំ២០០៣។ អត្រាគ្របដណ្ដប់កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន (PMTCT) បានកើនពី៩៣,២% នៅឆ្នាំ២០២៣ ទៅ៩៧,២% នៅឆ្នាំ២០២៤។ អត្រាឆ្លងមេរោគអេដស៍ពីម្ដាយទៅកូនក៏បានធ្លាក់ចុះពី ៨,៤% ក្នុងឆ្នាំ២០២៣ មកនៅត្រឹមតែ ៦,៩% ក្នុងឆ្នាំ២០២៤។ នៅត្រីមាសទី៣ ឆ្នាំ២០២៥ មានអ្នកផ្ទុកមេរោគអេដស៍កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ចំនួន

៧១៧១៦នាក់ នៅតាមសេវាព្យាបាលជំងឺអេដស៍ចំនួន៧៤កន្លែងទូទាំងប្រទេស។ ត្រឹមខែទី៣ ឆ្នាំ២០២៥ អ្នកផ្ទុកមេរោគអេដស៍ចំនួន ៥៣ ៨២១នាក់ ស្មើនឹង៧៥% នៃអ្នកផ្ទុកមេរោគអេដស៍ចំនួន ៧១ ៧១៦នាក់ អ្នកដែលមកទទួលសេវាថែទាំព្យាបាល បានទទួលបណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) នៅតាមមូលដ្ឋានសុខាភិបាលទូទាំង២៥ រាជធានី ខេត្ត។

សន្ទស្សន៍នៃការរើសអើង មាក់ងាយអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍មានការថយចុះខ្លាំងគួរជាទីមោទនៈ។

ទាំងនេះ គឺជាជោគជ័យដ៏ត្រចះត្រចង់ ដែលយើងសម្រេចបាននាពេលកន្លងមក ប៉ុន្តែស្ថានភាពនៃបញ្ហារាលដាលមេរោគអេដស៍/ជំងឺអេដស៍ ក៏នៅតែមានភាពផុយស្រួយនៅឡើយ។ ល្ពឹកណាកម្ពុជាយើងមិនទាន់ឈានដល់ដំណាក់កាលនៃការបញ្ចប់អេដស៍ ដែលកំណត់ការឆ្លងថ្មីក្នុងរង្វង់ជាង២០០ករណីក្នុងមួយឆ្នាំ ការឆ្លងមេរោគអេដស៍អាចផ្ទុះឡើងវិញគ្រប់ពេលវេលា ព្រោះថាមេរោគអេដស៍អាចរីករាលដាលឡើងវិញដោយសារការសប្បាយភ្លើតភ្លើន និងដោយសារការសេពគ្រឿងស្រវឹង និងគ្រឿងញៀន ដែលនាំទៅរកការត្រេកត្រអាលក្នុងការរួមភេទដោយធ្វេសប្រហែសជាក្រុម ឬជាមួយដៃគូអនាមិកដែលគេមិនធ្លាប់ស្គាល់ ឬជាមួយអ្នករកស៊ីផ្លូវភេទដែលពុំមានការយល់ដឹងអំពីវិធីបង្ការការពារទប់ស្កាត់ មេរោគអេដស៍។

ដូចនេះ សូមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងបណ្តាញប្រជាជនគន្លឹះ ក៏ដូចជាបងប្អូនជនរួមជាតិទាំងអស់ បន្តការយកចិត្តទុកដាក់ឱ្យបានខ្ពស់ និងចូលរួមឱ្យបានកាន់តែសកម្មថែមទៀតជាមួយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយហានិភ័យខាងលើឱ្យមានប្រសិទ្ធភាព និងទាន់ពេលក្នុងដំណើរការឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នាឆ្នាំ២០២៨។ ការបញ្ចប់បញ្ហាអេដស៍ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ គឺជាអាទិភាពមួយនៃការអភិវឌ្ឍមូលធនមនុស្សដែលបានចែងក្នុងបញ្ចកោណទី១ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងការរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ កសាងសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងប្រទេសជាតិឱ្យមានការ វិវត្តន៍រីកចម្រើនឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងប្រទេសឱ្យក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

**អង្គពិធីនាំងមូលជាទីមេត្រី**!

ក្នុងដំណើរឆ្ពោះទៅសម្រេចគោលដៅលុបបំបាត់ជំងឺអេដស៍ និងធ្វើឱ្យមាននិរន្តរភាព និងចីរភាពកម្មវិធីអេដស៍នៅកម្ពុជា គឺពិតជាមានការលំបាក និងស្មុគស្មាញមែន ប៉ុន្តែយើងអាចធ្វើបានតាមរយៈការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការចូលរួមពីគ្រប់សមាសភាពសង្គមប្រកបដោយការប្តេជ្ញាចិត្តយ៉ាងមោះមុតរួមគ្នា និងជម្នះឱ្យបាននូវរាល់ឧបសគ្គនានា ដែលអាចកើតមានឡើង ដូចជា៖ កង្វះធនធាន ការរើសអើង មាក់ងាយ វិសមភាពនៃការផ្តល់និងទទួលសេវា គម្លាតរវាងការបង្ការ និងថែទាំព្យាបាលជាដើម។

ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមប្រកាសជាឱឡារិកថា រាជរដ្ឋាភិបាលកម្ពុជា នៅតែចាត់ទុកការងារប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាជាអាទិភាពខ្ពស់ ដូចមានចែងនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាថា ប្រទេសកម្ពុជាគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ ប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាចដោយសារជំងឺអេដស៍។

ឆ្លៀតក្នុងឱកាសចូលរួមអបអរសាទរទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ ឆ្នាំ២០២៥នេះ ក្នុងនាម **សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមផ្តល់នូវការណែនាំបន្ថែមមួយចំនួនដូចតទៅ៖

ទី១.អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ណែនាំ ជួយសម្រួលឱ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល និងបណ្តាញជាដៃគូ មន្ទីរពាក់ព័ន្ធ(ផែនការ ទេសចរណ៍ សុខាភិបាល) និងបេឡាជាតិសន្តិសុខសង្គម ជំរុញប្រជាជនគន្លឹះបម្រើការក្នុងសេវាកម្សាន្តទេសចរណ៍ មានជាអាទិ៍ បុរសរួមភេទជាមួយបុរស(MSM) អ្នកបំប្លែងភេទ(TG) ស្ត្រីបម្រើក្នុងសេវាកម្សាន្ត(EW) មកធ្វើតេស្តរកមេរោគអេដស៍ ពិនិត្យព្យាបាលជំងឺកាមរោគនិងប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍នានា ព្រមទាំងពន្លឿនការរៀបចំចុះបញ្ជីផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) ដល់ប្រជាជនគន្លឹះទាំងនោះ ឱ្យបានយ៉ាងឆាប់រហ័ស និងបានទូលំទូលាយ។

ទី២.អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវប្រើប្រាស់ថវិកា ៨០លានរៀល ៦០លានរៀល ៤០លានរៀល ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានវិភាជជូនជារៀងរាល់ឆ្នាំលើការងារអេដស៍ ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពខ្ពស់។ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវបង្កើនភាពជាម្ចាស់ក្នុងដឹកនាំការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យទទួលបានជោគជ័យ។

ទី៣.អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ត្រូវណែនាំរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ លើកផែនការសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងប្រើប្រាស់ថវិកាតាមសារាចរអន្តរក្រសួងលេខ០០៧សហវ.ស.រ.អហក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ ស្តីពីការគ្រប់គ្រងការចាត់ចែង និងការកំណត់មុខសញ្ញាចំណាយថវិកាសេវាសង្គម និងអនាម័យបរិស្ថាន នៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ដើម្បីទទួលបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព។

ទី៤.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្តត្រូវជំរុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ តាមរយៈកិច្ចប្រជុំ ផ្សព្វផ្សាយ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ដើម្បីបញ្ជ្រាបការយល់ដឹងអំពីហានិភ័យមេរោគអេដស៍និងជំងឺអេដស៍ និងការមាក់ងាយ រើសអើង ដោយទាក់ទាញនិងលើកទឹកចិត្ត

ដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ឱ្យបានទាន់ពេលវេលា និងទូលំទូលាយ។

ទី៥.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តស្វែងរកជំនួយ និងហិរញ្ញប្បទានសហប្រតិបត្តិការពីអន្តរជាតិ ដៃគូអភិវឌ្ឍនានា និងវិស័យឯកជនដើម្បីគាំទ្រដល់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាពចីរភាព និងភាពធន់។

ទី៦.អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវបន្តសហការជាមួយក្រសួងសុខាភិបាលធ្វើការសិក្សារៀបចំយន្តការ និងយុទ្ធសាស្ត្រអន្តរាគមន៍ក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យបានតិចជាង៥% តាមការកំណត់ និងត្រូវរិះរកវិធីកាត់បន្ថយបន្ថែមទៀតនូវអត្រាបោះបង់ការព្យាបាល និងអត្រាស្លាប់របស់អ្នកផ្ទុកមេរោគអេដស៍ដែលកំពុងទទួលការព្យាបាល។ ជាមួយនេះ ក៏ត្រូវបន្តពង្រឹង និងបង្កើនកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាបន្ថែមទៀត ដើម្បីបង្ការ និងទប់ស្កាត់ឱ្យកាន់តែមានប្រសិទ្ធភាពនូវការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់និងអ្នកចាក់គ្រឿងញៀន។

ទី៧.ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តចូលរួមជំរុញការអប់រំ ផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីបង្ការការចម្លងមេរោគអេដស៍ក្នុងសហគមន៍ ជាពិសេសក្រុមប្រជាជនគន្លឹះរួមមាន ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកប្រើប្រាស់និងចាក់គ្រឿងញៀន ក្រុមស្ត្រីបម្រើការងារក្នុងគ្រឹះស្ថានកំសាន្តសប្បាយ និងក្រុមយុវវ័យទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ឱ្យទទួលបានព័ត៌មានទាន់ពេល និងការយល់ដឹងទូលំទូលាយ ដើម្បីការពារខ្លួនចៀសពីការឆ្លងមេរោគអេដស៍។

ទី៨.ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យលទ្ធភាពផ្តល់ថវិកាដល់ក្រសួង ស្ថាប័ន រាជធានី ខេត្តដែលបានលើកផែនការសកម្មភាព និងសូចនាករច្បាស់លាស់ ស្របតាមភារកិច្ច ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

ទី៩.ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវៈ

- បន្តផ្សព្វផ្សាយអំពីប្រសិទ្ធភាពនៃការប្រើស្រោមអនាម័យ១០០% ក្នុងការទប់ស្កាត់ការចម្លងមេរោគអេដស៍ពីដៃគូរួមភេទ
- ធានាឱ្យមានការរក្សាទុក និងការចែកចាយស្រោមអនាម័យឱ្យបានទូលំទូលាយ នៅតាមទីកន្លែងដែលមានការចាំបាច់នានា ជាពិសេសនៅក្នុងភូមិសាស្ត្រដែលមានបម្រើសេវា

កម្សាន្ត ដូចជារង្គសាល បៀរហ្គាដិន សណ្ឋាគារ ផ្ទះសំណាក់ ឬគ្រប់ទីកន្លែងដែលសង្ស័យថាអាចមានការរួមភេទ

- ហាមយកស្រោមអនាម័យជាភស្តុតាង ដើម្បីធ្វើការចោទប្រកាន់អំពីបទជួញដូរមនុស្ស។ ការប្រើស្រោមអនាម័យពាក់ព័ន្ធតែជាមួយការរួមភេទតែប៉ុណ្ណោះ។

ទី១០.គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូអន្តរជាតិ អង្គការជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជនទាំងអស់ បន្តយន្តការធ្វើការរួមគ្នាស្របតាមអភិក្រម «**ឌីណាមិកនៃប្រព័ន្ធតួអង្គតែមួយ**» (Dynamics of Stakeholder System) ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន ឆ្ពោះទៅបញ្ចប់អេដស៍នៅកម្ពុជា។

ទន្ទឹមនេះផងដែរ ក្នុងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ អង្គការសង្គមស៊ីវិលនានា វិស័យសាសនា វិស័យឯកជន សិល្បករ ពិធីករ កីឡាករ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធទប់ស្កាត់ និងលុបបំបាត់នូវការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ ជាមួយគ្នានេះ ខ្ញុំក៏សូមអំពាវនាវដល់សហគមន៍អន្តរជាតិដៃគូអភិវឌ្ឍន៍នានា សូមបន្តជួយគាំទ្រជាបច្ចេកទេស និងហិរញ្ញវត្ថុ ដល់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យកម្ពុជាយើងខ្ញុំអាចឈានទៅសម្រេចបានតាមគោលដៅដែលបានកំណត់ក្នុងគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។

ជាទីបញ្ចប់ និងនៅក្នុងឱកាសឆ្នាំថ្មី ឆ្នាំសកល២០២៦ ដែលនឹងឈានមកដល់ខាងមុខនេះ ខ្ញុំសូមប្រសិទ្ធពរជូន សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗយុវជន និងអង្គពិធីទាំងមូល សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសជាឱឡារិកថាកម្ពុជាប្រកាន់យកប្រធានបទ «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» ដើម្បីឆ្ពោះទៅបញ្ចប់អេដស៍ជាការគំរាមកំហែងដល់សុខភាពសាធារណៈ។

*សូមអរគុណ!*